# ការកសាងឡើងវិញនូវប្រព័ន្ធតុលាការកម្ពុជា

## ការបង្កើនសមត្ថភាពរបស់ចៅក្រមកម្ពុជា តាមរយៈកម្មវិធីទ្រទ្រង់តុលាការរបស់ការិយាល័យOHCHR



Photo: OHCHR Cambodia

សវនាការនៅតុលាការរាជធានីភ្នំពេញ កម្ពុជា

កាលគាត់ចាប់យកអាជីពជាចៅក្រមដំបូងនៅតុលាការ កាលណាគាត់មានចម្ងល់ណាមួយស្តីពីបញ្ហាខាងនីតិវិធី ឬអំពីការអនុវត្តច្បាប់ជាក់លាក់ណាមួយ លោកចៅក្រម ហ៊ីង ធីរិទ្ធ តែងតែបានសួរទីប្រឹក្សាច្បាប់របស់លោកនៅសាលាដំបូងរាជធានីភ្នំពេញអំពីបញ្ហានីតិវិធី ឬអំពីបញ្ហាច្បាប់នេះ។ លោកគឺជាចៅក្រមមួយរូប ក្នុងចំណោមចៅក្រមរាប់សិបនាក់ ដែលរវាងឆ្នាំ ១៩៩៥ និងឆ្នាំ២០០២ លោកបានទទួលគុណប្រយោជន៍ពីកម្មវិធីទ្រទ្រង់តុលាការរបស់ការិយាល័យ OHCHR ដែលជាគំនិតផ្តួចផ្តើមក្នុងគោលបំណងជួយរដ្ឋាភិបាលថ្មីរបស់កម្ពុជា ក្នុងការកសាងឡើងវិញ និងធ្វើកំណែទម្រង់ប្រព័ន្ធតុលាការរបស់ខ្លួនដែលមិនទាន់រឹងដៃរឹងជើងនៅឡើយ។

វិស័យយុត្តិធម៌កម្ពុជាបានប្រឈមនឹងបញ្ហាជាច្រើន មិនត្រឹមតែកង្វះនូវបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាល ដែលជាបច្ច័យកើតមកពីការធ្វើទុក្ខបុកម្នេញអស់រយៈពេលជាច្រើនឆ្នាំ ដល់អ្នកទាំងឡាយ ដែលគេចាត់ទុកជា "បញ្ញវន្ត"។ ដើម្បីជួយកែតម្រូវស្ថានភាពនេះ និងដើម្បីជួយដល់ចៅក្រមដែលទើបបានតែងតាំងថ្មី ការិយាល័យ OHCHR បានផ្តល់ជំនួយបច្ចេកទេសដល់តុលាការក្នុងស្រុកនូវទីប្រឹក្សាច្បាប់ ដែលជាចៅក្រម ឬមេធាវីមានបទពិសោធន៍ពីប្រទេសផ្សេងៗ ដែលបានផ្តល់ប្រឹក្សាយោបល់ និងការបណ្តុះបណ្តាលប្រចាំថ្ងៃដល់ចៅក្រម ព្រះរាជអាជ្ញា និងបុគ្គលិកផ្សេងៗទៀតរបស់តុលាការ អំពីបញ្ហារដ្ឋបាលនិងច្បាប់ ដោយផ្តោតលើការអនុវត្តបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិក្នុងការងាររបស់ខ្លួន។ ទីប្រឹក្សាច្បាប់អាចធ្វើការតាមឃ្លាំមើល និងពិនិត្យពិច័យផងដែរនូវភាពមិនប្រក្រតី កំណត់បញ្ហានានា និងស្នើឲ្យមានដំណោះស្រាយដោយផ្ទាល់ទៅចៅក្រម។ កម្មវិធីនេះបានទទួលការគាំទ្រពេញទំហឹងពីក្រសួងយុត្តិធម៌ ដែលបានស្នើសុំឲ្យកម្មវិធីនេះពង្រីកវិសាលភាពបន្ថែម ដើម្បីបានទៅដល់ស្ថាប័នជាច្រើនទៀត។

កាលពីប្រកាសបើកឲ្យដំណើរការដំបូង ដែលមានការរួមវិភាគទាន ២០០.០០០ ដុល្លារ ពីប្រទេសជប៉ុនទៅក្នុងមូលនិធិអង្គការសហប្រជាជាតិ សម្រាប់ការអប់រំសិទ្ធិមនុស្សនៅកម្ពុជា ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក កម្មវិធីនេះបានពង្រីកគ្របដណ្តប់លើចំនួនសរុប ១៦ តុលាការ រាប់ទាំងតុលាការខេត្តនិងក្រុងព្រមទាំងតុលាការកំពូល និងសាលាឧទ្ធរណ៍។ កម្មវិធីនេះបានធ្វើប្រតិបត្តិការក្នុងខេត្តចំនួន ១៣ រួមមានខេត្តបាត់ដំបង កំពង់ចាម កំពង់ឆ្នាំង តាកែវ ស្វាយរៀង និងតុលាការរាជធានីភ្នំពេញ។ មានការផ្តល់ប្រឹក្សាយោបល់លើករណីច្រើនរាប់មិនអស់ ដែលក្នុងនោះភាគច្រើន មានការអនុវត្តតាមបទដ្ឋានជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌បន្ទាប់ពីការផ្តល់ប្រឹក្សាយោបល់ និងបានជួយសម្រួលដល់សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបាននូវត្តិធម៌ដែលជារឿយៗតែងតែឃើញមានករណីចាប់ខ្លួន ឬឃុំខ្លួនខុសច្បាប់ ត្រូវបានដោះលែងឲ្យមានសេរីភាពវិញ។

> "ទីប្រឹក្សាច្បាប់បានជួយដល់ចៅក្រមឲ្យផ្តោតលើច្បាប់ នៅពេលឈានទៅសម្រេចរឿងក្តីរបស់ខ្លួន និងបានកាត់បន្ថយការរំលោភសិទ្ធិមនុស្ស និងការឃុំខ្លួនតាមអំពើចិត្ត"។
>
> លោក ហ៊ីង ធីរិទ្ធ
>
> អតីតចៅក្រម សាលាដំបូងរាជធានីភ្នំពេញ

*ខែមិថុនា*